# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជានៅអំពៅព្រៃ
# ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៨
## *អាកប្បកិរិយាទាំង១០ ដើម្បីរៀបចំចិត្តគំនិត*

អត្ថបទទី១៖ សផ ៣,១៤-១៨ក
អត្ថបទទី២៖ ភីល ៤,៤-៧
ដំណឹងល្អ៖ លក ៣,១០-១៨

បងប្អូនជាទីស្រឡាញ់!

យើងចូលនៅក្នុងរដូវរង់ចាំព្រះយេស៊ូប្រសូត ម្សិលមិញខ្ញុំបានជួបជាមួយចាស់ៗច្រើននៅផ្ទះបងស្រីមេត្តាករុណា មានទាំងពុទ្ធបរិស័ទ គ្រីស្តបរិស័ទ អ៊ីស្លាមបរិស័ទ។ នៅយប់បុណ្យព្រះយេស៊ូប្រសូត យើងជាគ្រួសារតែមួយដោយសារជាព្រះយេស៊ូដែលណែនាំឲ្យមនុស្សទាំងអស់នៅក្នុងពិភពលោកទាំងមូល ត្រូវតែមានពោរពេញដោយអំណរសប្បាយនិងសេចក្តីស្រឡាញ់។ នៅក្នុងពិភពលោករបស់យើងខ្វះសេចក្តីស្រឡាញ់ ជាមូលហេតុធ្វើឲ្យមានសង្គ្រាម មានបញ្ហាជាមួយគ្នា។ លោកយ៉ូហានបាទីស្ទនិយាយថា "**ខ្ញុំបន្តប្រកាសដំណឹងល្អ**" ដំណឹងល្អមានន័យថាជាដំណឹងដែលណែនាំឲ្យយើសប្បាយចិត្ត។ ព្រះយេស៊ូយាងមក ដើម្បីឲ្យយើងស្តាប់ដំណឹងល្អដែលណែនាំឲ្យយើងសប្បាយចិត្ត ណែនាំឲ្យយើងមានសេចក្តីសង្ឃឹម ណែនាំឲ្យយើងទទួលជីវិតដ៏បរិបូណ៌។

ពេលយើងចូលព្រះវិហារ យើងស្តាប់ដំណឹងល្អដើម្បីណែនាំឲ្យយើងពោរពេញដោយសេចក្តីសុខ។ ដំណឹងល្អដែលយើងស្តាប់ថ្ងៃនេះ គឺព្រះយេស៊ូយាងមកដើម្បីណែនាំឲ្យយើងទាំងអស់ពោរពេញដោយសេចក្តីស្រឡាញ់។ ប៉ុន្តែ ដើម្បីទទួលដំណឹងល្អនេះយើងត្រូវការរៀបចំចិត្តគំនិតយើងចាំមួយខែមុនសម្រាលកូនក្រោយពេលយើងមានផ្ទៃពោះ ណែនាំឲ្យយើងភ័យផង សប្បាយផង តែយើងបានរៀបចំខ្លួនរួចជាស្រេច។ ព្រះនាងម៉ារីក៏ដូចគ្នា គាត់កំពុងរៀបចំខ្លួនទទួលស្វាគមន៍ព្រះយេស៊ូដែលប្រសូត សម្រាប់យើងទាំងអស់គ្នាក៏ដូចគ្នាដែរ យើងត្រូវការរៀបចំចិត្តគំនិត។ ខ្ញុំមាន១០យ៉ាងនៃអាកប្បកិរិយា ដើម្បីរៀបចំចិត្តគំនិត៖

**ទី១ ឲ្យយើងជឿ ជឿលើព្រះជាម្ចាស់** ឲ្យយើងទុកចិត្តលើព្រះជាម្ចាស់ បើយើងមិនទុកចិត្តលើព្រះជាម្ចាស់យើងមិនអាចទៅមុខបានទេ។ ព្រះជាម្ចាស់ ជាព្រះបិតាដែលស្រឡាញ់យើង ព្រះនាងម៉ារី ពេលទេវទូតកាព្រីអែលបានប្រាប់ថា ធ្វើជាម្តាយរបស់ព្រះជាម្ចាស់ ព្រះនាងម៉ារីបានឯកភាពដោយសារគាត់មានជំនឿលើព្រះជាម្ចាស់ ដោយដឹងថាព្រះជាម្ចាស់ការពារថែរក្សានិងស្រឡាញ់គាត់។ ពេលយើងស្តាប់ព្រះបន្ទូល យើងដឹងថាព្រះជាម្ចាស់ស្រឡាញ់យើង។

**ទី២ ឲ្យយើងស្វែងរកព្រះយេស៊ូ និងព្រះជាម្ចាស់** នៅពេលយើងស្តាប់ព្រះបន្ទូលព្រះជាម្ចាស់បំភ្លឺយើងឲ្យយើងឃើញព្រះអង្គ ពេលយើងជួបជាមួយបងប្អូនឯទៀតៗយើងឃើញព្រះជាម្ចាស់ដែរ។ ព្រះជាម្ចាស់ មានវត្តមាននៅក្នុងមនុស្សទាំងអស់ ណែនាំឲ្យយើងចេះគោរពបងប្អូនឯទៀតៗ ទៅជាសាសនាណាក្តីឲ្យយើងចេះគោរពគ្នាទៅវិញទៅមក។

**ទី៣ ឲ្យយើងមានចិត្តសប្បុរស** ដែលចេះអាណិតមេត្តាបងប្អូនឯទៀតៗ បើយើងមិនចេះមើលនៅក្នុងភូមិរបស់យើង បើយើងមិនចេះមើលអ្វីដែលកើតឡើងនៅជុំវិញខ្លួនយើង បើយើងគ្មានចិត្តសប្បុរស គ្មានចិត្តអាណិតមេត្តា យើងមិនអាចដើរតាមព្រះយេស៊ូបានទេ។ ព្រះយេស៊ូណែនាំឲ្យយើងមានចិត្តអាណិតមេត្តាជានិច្ច។

**ទី៤ ការសម្រុះសម្រួល** ជួនកាលយើងអន់ចិត្តគ្នា ឲ្យយើងធ្វើយ៉ាងណាសម្រុះសម្រួលគ្នាដើម្បីទៅមុខ។ ឲ្យយើងសម្រុះសម្រួលគ្នា ដើម្បីលើកលែងទោសឲ្យគ្នាទៅវិញទៅមក ដោយយល់ថាព្រះជាម្ចាស់យាងមកឲ្យយើងទៅជាគ្រួសារតែមួយ។ ជាគ្រួសារដែលចេះស្តាប់គ្នា យល់ចិត្តគ្នា លើកលែងទោសឲ្យគ្នា ដោយបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធ។

**ទី៥ ការប្រព្រឹត្តស្របគ្នា** នៅពេលយើងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ឲ្យយើងខិតខំអនុវត្តតាមព្រះបន្ទូលនោះ។ នៅពេលយើងស្តាប់ព្រះបន្ទូលរួចហើយ ឲ្យយើងគិតថាខ្ញុំបានស្តាប់ព្រះបន្ទូលនេះឲ្យខ្ញុំធ្វើដូចម្តេចដើម្បីអនុត្តព្រះបន្ទូលនេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំ។

**ទី៦ សេចក្តីស្រឡាញ់** ប្រសិនបើគ្មានសេចក្តីស្រឡាញ់នៅក្នុងពិភពលោកសុទ្ធតែសង្គ្រាម។ មានតែសេចក្តីស្រឡាញ់ដែលណែនឲ្យយើងទៅមុខ យើងធ្វើយ៉ាងណាឲ្យកន្លែងយើងទៅជាកន្លែងដែលពោរពេញដោយសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដ។

**ទី៧ ឲ្យយើងចេះអរព្រះគុណ** ដល់ព្រះជាម្ចាស់ ដឹងគុណដល់ឪពុកម្តាយ ដល់បងប្អូន ដល់ព្រះសហគមន៍។ ជួនកាលយើងចេះតែសុំ ឲ្យយើងចេះដឹងគុណ ឲ្យយើងចេះសងគុណ យើងទូលអង្វរផង ឲ្យអរព្រះគុណព្រះជាម្ចាស់ផង។

**ទី៨ ប្រកាសដំណឹងល្អ** កុំឲ្យយើងខ្មាស់ក្នុងការប្រកាសដំណឹល្អរបស់ព្រះយេស៊ូគ្រីស្ត ធ្វើដូចម្តេចដើម្បីឲ្យព្រះសហគមន៍របស់យើងចេះប្រកាសដំណឹងល្អ ដោយឥរិយាបងរបស់យើងប្រកាសតាមរបៀបដែលយើងរស់នៅជាប្រចាំថ្ងៃ។

**ទី៩ ឲ្យយើងធ្វើជាពន្លឺ** ឲ្យយើងធ្វើជាផ្កាយមួយសម្រាប់បងប្អូនឯទៀតៗ ដើម្បីឲ្យព្រះសហាគមន៍របស់យើង ពិភពលោករបស់យើងពោរពេញដោយពន្លឺ ឲ្យជីវិតរបស់យើងទៅជាពន្លឺយ៉ាងតូចមួយសម្រាប់អ្នកដទៃ។

**ទី១០ ឲ្យយើងអធិដ្ឋានជានិច្ច** បើយើងមិនចេះអធិដ្ឋានយើងឥតមានកម្លាំង អធិដ្ឋានណែនាំឲ្យយើងមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីរស់នៅនៅក្នុងគ្រួសាររបស់យើងដែលជាព្រះសហាគមន៍។

នេះជាអាកប្បកិរិយា ទាំង១០យ៉ាងដែលយើងត្រូវចាំអស់មួយជីវិតរបស់យើង យើងធ្វើយ៉ាងណាដើម្បីឲ្យបុណ្យព្រះយេស៊ូប្រសូត ទៅជាបុណ្យនៃសេចក្ដីស្រឡាញ់ ដែលណែនាំឲ្យព្រះសហាគមន៍របស់យើងពោរពេញដោយសេចក្ដីស្រឡាញ់ ដើម្បីណែនាំឲ្យមនុស្សលោកពោរពេញដោយសេចក្ដីសុខ ដោយដឹងថានៅទីនេះមានផ្កាយតូចៗច្រើន។ សូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គជួយយើង ដើម្បីឲ្យព្រះសហាគមន៍យើងទៅជាព្រះសហាគមន៍របស់ព្រះគ្រីស្ដ ដែលចេះសម្រុះសម្រួល និងស្រឡាញ់គ្នាជាមហាគ្រួសាររបស់ព្រះគ្រីស្ដ។ អាម៉ែន៕